San Diego Unified
SCHOOL DISTRICT

Office of Language Acquisition
EUGENE BRUCKER EDUCATION CENTER
4100 Normal Street, Room 2009
San Diego, CA 92103-2682
Phone: (619) 725-7266

ខែ មេសា ឆ្នាំ ២០១៧

មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សរៀន អង់គ្លេស ជាទីរាប់អាន:

ច្បាប់រដ្ឋ និងសហព័នតម្រូវអោយក្រសួងអប់រំប្រចាំក្រុងទាំងអស់ក្នុងរដ្ឋ California ផ្ដល់ការប្រឡងវិញ្ញាសារខាងផ្នែកភាសារ អង់គ្លេស ជារៀងរាល់ឆ្នាំដលសិស្សគ្រប់រូបដែលបញ្ជាក់ថាជាសិស្សរៀន អង់គ្លេស។ រដ្ឋ California ឈ្មោះនៃការប្រឡងវិញ្ញាសារគេហៅថា ការប្រឡងវិញ្ញាសារបណ្ដុះបណ្ដាលភាសា អង់គ្លេស (CELDT). លទ្ធផលនៃការប្រឡងវិញ្ញាសារ CELDT អាចយកមកជួយធ្វើការវាស់ស្ទង់កំរិតនៃការសិក្សារបស់សិស្សម្នាក់ៗរៀនភាសារ អង់គ្លេស ខាងផ្នែកការស្ដាប់, ការនិយាយ, ការអាន, និងការសរសេរ។ ការប្រឡងវិញ្ញាសារ CELDT នេះគឺជាការតម្រូវមួយដើម្បីយកមកប្រើប្រាស់រៀបចំចំណាត់ថ្នាក់អោយសិស្សសិក្សា។

ចាប់ពីឆ្នាំសិក្សា ២០១៧-២០១៨ រដ្ឋ California នឹងបញ្ចេញវិញ្ញាសារប្រឡងថ្មីផ្នែកភាសារ អង់គ្លេស ដែលហៅថា វិញ្ញាសារប្រឡងការវាស់ស្ទង់ភាសារ អង់គ្លេស សំរាប់ California (ELPAC), ដែលជំនួសវិញ្ញាសារប្រឡង CELDT ។ លទ្ធផលនៃការប្រឡងវិញ្ញាសារ ELPAC នឹងបន្តការវាស់ស្ទង់កំរិតការសិក្សា អង់គ្លេស របស់សិស្សខាងផ្នែក ការស្ដាប់, ការនិយាយ, ការអាន, និងការសរសេរ ព្រមទាំង វានឹងយកមកប្រើប្រាស់តម្រូវសំរាប់ការរៀបចំចំណាត់ថ្នាក់សិស្សផងដែរ។ ពេលនេះ រដ្ឋ California មិនទាន់ចេញផ្សាយនូវលក្ខណៈវិនិច្ឆ័យនៃតម្រូវថ្មីនេះឡើយ។

កាលពីឆ្នាំកន្លងផុតទៅ ការប្រឡងវិញ្ញាសារ CELDT ធ្វើឡើងនៅចន្លោះខែ កក្កដា និង ខែ តុលា។ ជាមួយនឹងការផ្លាស់ប្ដូរ ELPAC,ពេលនេះការប្រឡងវិញ្ញាសារថ្មីនេះនឹងធ្វើឡើងចន្លោះខែ កម្ភៈ និងខែ មិនា ឆ្នាំ ២០១៨។ លោកគ្រូ-អ្នកគ្រូ, បុគ្គលិកសាលារៀន
និងបុគ្គលិកក្រសួងអប់រំប្រចាំក្រុងនឹងទទួលការហ្វឹកហ្វឺននូវរបៀបគ្រប់ការប្រឡងវិញ្ញាសារនេះនៅខែ មករា និងខែ កម្ភៈ ឆ្នាំ ២០១៨។

បើអ្នកមានសំនួរបន្ថែមស្ដីអំពី ELPAC យើងសូមអោយអ្នកធ្វើការទាក់ទងសាលារៀនរបស់អ្នក ឬការិយាល័យទាក់ទងផ្នែកភាសារ ola@sandi.net ។ បន្ថែមយើងស្វាគមន៍ដល់អ្នកជួយស្ម័គ្រចិត្តបំរើដល់សាលារៀន និងចូលរួមជាមួយគណៈកម្មាការណែនាំសិស្សរៀន អង់គ្លេស នៅតាមសាលារៀន (ELAC) ដើម្បីបន្តទទួលពត៌មានថ្មីៗ អំពី

ELPAC ។ បើអ្នកមានសំនួរអ្វីមួយស្ដីអំពី ពិន្ទុប្រឡងវិញ្ញាសារ CELDT អោយបានជាប់, ការរៀបចំចំណាត់ថ្នាក់សិស្សឡើងវិញ ឬចំណាត់ថ្នាក់សំរាប់កូនអ្នកសិក្សា, សូមធ្វើការទាក់ទងសាលារៀននៅម៉ោងធ្វើការ។

ដោយក្ដីរាក់ទាក់បំផុត

Sandra S. Cephas
នាយក
ការិយាល័យគ្រប់គ្រងផ្នែកភាសារ
619-725-7266
ola@sandi.net

Cambodian Version.